ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៤៧ អនក្រ.សសរ

# សេចក្ដីសម្រេច
## ស្ដីពី
## ការបង្កើតគណៈកម្មការ សម្របសម្រួល និងគ្រប់គ្រងគំរោងផ្លូវជាតិលេខ ៣ ពីចោមចៅ (ភ្នំពេញ) ទៅដល់ទីរួមខេត្តកំពត

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**ប្រការ១ :** បង្កើតគណៈកម្មការសម្របសម្រួល និងគ្រប់គ្រងគំរោងផ្លូវជាតិលេខ ៣ ពីចោមចៅ (ភ្នំពេញ) ទៅដល់ទីរួមខេត្តកំពត ដែលមានសមាសភាពដូចខាងក្រោម:

| | | |
|---|---|---|
| ១-ឯកឧត្ដម ឌិត ចាន់ | អនុរដ្ឋលេខាធិការ ក្រសួងសាធារណការ និងដឹកជញ្ជូន | ប្រធាន |
| ២-ឯកឧត្ដម ទ័ព្វ វិសុទ្ធ | អគ្គលេខាធិការរង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣-លោក ទាំ ស៊ីមសុរិយា | ប្រធាននាយកដ្ឋានផែនការ ក្រសួងសាធារណការនឹងដឹកជញ្ជូន | សមាជិក |
| ៤-បណ្ឌិត ជា វ៉ាន់ដេត | អនុប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ គ.រ.ម. | សមាជិក |
| ៥-លោក គឹម បូរី | នាយករងមជ្ឈមណ្ឌលស្រាវជ្រាវបច្ចេកទេសសាធារណការ ក្រសួងសាធារណការនិងដឹកជញ្ជូន | សមាជិក |
| ៦-លោក ចៅ យុនថា | ប្រធានការិយាល័យសហប្រតិបត្តិការទ្វេភាគី ស.ហ.វ. | សមាជិក |

**ប្រការ២ :** គណៈកម្មការនេះមានភារកិច្ចសម្របសម្រួល និងគ្រប់គ្រង គំរោងស្ដាបនាផ្លូវជាតិលេខ ៣ ពីចោមចៅ (ភ្នំពេញ) ទៅដល់ទីរួមខេត្តកំពត ក្រោមហិរញ្ញប្បទាននៃឥណទានសម្បទានរបស់រដ្ឋាភិបាលសាធារណរដ្ឋកូរ៉េ រហូតដល់ការអនុវត្តគំរោងនេះត្រូវបានបញ្ចប់ ។

**ប្រការ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ នឹងដឹកជញ្ជូន និងសាមីខ្លួន ដែលមានចែងក្នុងប្រការមួយ ត្រូវអនុវត្តសេចក្ដីសំរេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែ មេសា ឆ្នាំ ២០០៤*
នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចចែងក្នុងប្រការ ៣
- ឯកសារ-កាលប្បវត្តិ